តារាងប្រតិបត្តិការហិរញ្ញវត្ថុ និង សេដ្ឋកិច្ច
TOFE / GFS

1 2 3 4 5 >

ប្រកាសព័ត៌មាន
Publications

- ចរិកាសង្ខេប Budget in Brief
- តារាងប្រតិបត្តិការហិរញ្ញវត្ថុ និង សេដ្ឋកិច្ច TOFE / GFS
- និន្នាការសេដ្ឋកិច្ចសង្គម Flash Report
- ព្រឹត្តិប័ត្រស្ថិតិប្រចាំខែ Statistic Bulletin
- ថ្លៃទំនិញ Market Price
- ស្ថានភាពអតិផរណា Inflation Report
- លិខិតប្រកាសពន្ធគ្រប់ប្រភេទ នៃអគ្គនាយកដ្ឋានពន្ធដារ Tax Return Forms of General Department of Tax

តារាងប្រតិបត្តិការហិរញ្ញវត្ថុ និង សេដ្ឋកិច្ចសម្រាប់ ខែ វិច្ឆិកា ឆ្នាំ ២០១៥ (TOFE for November 2015)
នៅ១១ខែដើមឆ្នាំ២០១៥ ស្ថានភាពម៉ាក្រូសេដ្ឋកិច្ចមានស្ថិរភាពល្អ ដូចជាស្ថិរភាពអត្រាប្តូរប្រាក់ និងអតិផរណាមានកម្រិតទាប។ ចំណែកសកម្មភាពសេដ្ឋកិច្ចនៅតាមវិស័យមួយចំនួននៅតែបន្តរុញច្រានកំណើនដូចជាវិស័យកាត់ដេរ វិស័យសំណង់ និងវិស័យអគ្គីសនីជាដើម។ ទន្ទឹមនឹងនេះ គម្រោងវិនិយោគដែលបានអនុម័តបង្ហាញថា ទឹកប្រាក់វិនិយោគបានកើនឡើង ពិសេសគឺដោយសារកំណើនវិនិយោគទុនក្នុងស្រុក។ ចំណែកការអនុវត្តថវិកាបានបង្ហាញនូវជំហរឆ្ពោះទៅមុខយ៉ាងស្វាហាប់នៅលើរបត់នៃកំណែទម្រង់ ក្នុងនោះមានការខិតខំពង្រឹងខាងផ្នែកចំណូល និងការកែលម្អនីតិវិធីនៃការអនុវត្តចំណាយទៅតាមការអនុវត្តចំណាយទៅតាមការអនុវត្តថវិកាកម្មវិធី និងការអនុវត្តអង្គភាពថវិកា ដែលបានចាប់ផ្តើមនៅឆ្នាំ២០១៥ នេះ។

[ព័ត៌មានលម្អិត ...] កាលបរិច្ឆេទ៖ February 05, 2016

តារាងប្រតិបត្តិការហិរញ្ញវត្ថុ និង សេដ្ឋកិច្ចសម្រាប់ ខែ តុលា ឆ្នាំ ២០១៥ (TOFE for October 2015)
នៅ១០ខែ ដើមឆ្នាំ២០១៥ ស្ថានភាពម៉ាក្រូសេដ្ឋកិច្ចមានស្ថិរភាពល្អ ដូចជាការកើនឡើងវិនិយោគទុន ស្ថិរភាពអត្រាប្តូរប្រាក់ និងអតិផរណាមានកម្រិតទាប ។ ចំណែកសកម្មភាពសេដ្ឋកិច្ចនៅតាមវិស័យនីមួយៗ នៅតែបន្តកើនឡើងល្អ ដូចជា វិស័យកាត់ដេរនិងស្បែកជើង វិស័យសំណង់ និងវិស័យអគ្គិសនី ជាដើម ទន្ទឹមនឹងមានស្ថេរភាពលើវិស័យហិរញ្ញវត្ថុ។ អតិផរណាលើអាហារបន្តកើនឡើង ប៉ុន្តែក្នុងកម្រិតទាប ដោយសារការធ្លាក់ចុះតម្លៃប្រេងលើទីផ្សារអន្តរជាតិ។ ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុខាងលើ គឺមានឥទ្ធិពលជាវិជ្ជមានក្នុងការអនុវត្តថវិកា ជាពិសេសការកើនឡើងនៃចំណូល និងការចំណាយទាន់ពេលវេលា។

[ព័ត៌មានលម្អិត ...] កាលបរិច្ឆេទ៖ January 12, 2016

តារាងប្រតិបត្តិការហិរញ្ញវត្ថុ និង សេដ្ឋកិច្ចសម្រាប់ ខែ កញ្ញា ឆ្នាំ ២០១៥ (TOFE for September 2015) នៅឆ្នាំ ២០១៥ ស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច នៅប្រទេសកម្ពុជា នៅរក្សាបានជាប្រក្រតី។ កំណើនសេដ្ឋកិច្ចអាចនិងសម្រេចបានតាមការគ្រោង ដែលកំណើននេះត្រូវបានគាំទ្រពីខាងតម្រូវការប្រើប្រាស់ក្នុងប្រទេស ពីវិស័យសំណង់ និងអចលនទ្រព្យ បើទោះបីជាវិស័យទេសចរណ៍និងកសិកម្ម មានការរីកលូតលាស់ ទាបជាងការរំពឹងទុកក៏ដោយ។ ចំណែកចំណូលពីសារពើពន្ធ និងគយ មានការកើនឡើង ដោយសារការខិតខំបង្កើនប្រសិទ្ធភាពលើការប្រមូលពន្ធ ការកែទម្រង់រដ្ឋបាលផ្សេងៗ និងកំណើនតម្រូវការទំនិញលើទីផ្សារ។ ការចំណាយត្រូវ បានបន្តត្រួតពិនិត្យយ៉ាងម៉ត់ចត់ ក្នុងន័យបង្កើនប្រសិទ្ធភាព សន្សំសំចៃថវិកា និងការផ្តល់សេវាឱ្យកាន់តែប្រសើរឡើង។

[ព័ត៌មានលម្អិត ...] កាលបរិច្ឆេទ៖ November 18, 2015

តារាងប្រតិបត្តិការហិរញ្ញវត្ថុ និង សេដ្ឋកិច្ចសម្រាប់ ខែ សីហា ឆ្នាំ ២០១៥ (TOFE for August 2015) នៅឆ្នាំ ២០១៥ កំណើនសេដ្ឋកិច្ចកម្ពុជារំពឹងថា នឹងសម្រេចតាមការប៉ាន់ប្រមាណ ដែលកំណើននេះអូសទាញដោយវិស័យ ឧស្សាហកម្ម និងសេវាកម្ម ចំណែកវិស័យកសិកម្មបានកើនយឺតជាងការរំពឹងទុក។ វិស័យកាត់ដេរ និងស្បែកជើងនៅតែបន្តគាំទ្រ នៃការរីកលូតលាស់ ក្នុងវិស័យឧស្សាហកម្ម រីឯវិស័យសំណង់នៅតែពង្រីកកំណើនស្របពេលជាមួយនឹងនិន្នាការនៃនគរូបនីយកម្ម (urbanization) តាមរយៈកំណើននៃការហូរចូលឥណទាននិងវិនិយោគបរទេស។ អតិផរណាលើអាហារនៅតែបន្តកើនឡើង ប៉ុន្តែក្នុងកម្រិតទាបដោយសារការធ្លាក់ចុះតម្លៃប្រេងលើទីផ្សារអន្តរជាតិ ។ ទន្ទឹមនឹងនេះ ការងើបឡើងនសេដ្ឋកិច្ចកម្ពុជា ។ ចំណែក ចំណូលពីពន្ធជាពិសេសពន្ធលើតម្លៃបន្ថែមមានការកើនឡើង ដោយសាការខិតខំបង្កើនប្រសិទ្ធភាពលើការប្រមូលពន្ធ និងកណើននៃតម្រូវការទំនិញលើទីផ្សារ ។ ការចំណាយត្រូវបានបន្តត្រួតពិនិត្យយ៉ាងម៉ត់ចត់ ក្នុងន័យបង្កើនប្រសិទ្ធភាពសន្សំសំចៃថវិកា និងការផ្តល់សេវាអោយកាន់តែប្រសើរឡើង ។

[ព័ត៌មានលម្អិត ...] កាលបរិច្ឆេទ៖ October 12, 2015

តារាងប្រតិបត្តិការហិរញ្ញវត្ថុ និង សេដ្ឋកិច្ចសម្រាប់ ខែ មិថុនា ឆ្នាំ ២០១៥ (TOFE for June 2015) នៅពាក់កណ្តាលឆ្នាំ ២០១៥ គិតត្រឹមខែមិថុនា ស្ថានភាពម៉ាក្រូសេដ្ឋកិច្ចមានការគ្រប់គ្រង និងស្ថិរភាពល្អ ដូចជា ស្ថេរភាពអត្រាប្តូរប្រាក់ និង អតិផរណាមានកម្រិតទាប។ ចំណែកសកម្មភាពសេដ្ឋកិច្ចនៅតាមវិស័យនីមួយៗនៅតែបន្តកើនឡើងល្អ ដូចជាមានការកើនឡើងផ្នែកនាំចេញផលិតផលកសិកម្ម និងផលិតផលឧស្សាហកម្មនានា។ ប្រទេសកម្ពុជាហាក់បីដូចជាមិនសូវមានផលប៉ះពាល់ពីការទម្លាក់ថ្លៃលុយយ័នរបស់ចិននៅឡើយ បើទោះបីជាប្រទេសកម្ពុជាធ្វើការនាំចេញផលិតផលគិតជាដុល្លារក្តី។ ផ្ទុយទៅវិញ វត្ថុធាតុដើមដែលនាំចូលមកពីចិនមានតម្លៃថោកជាងមុន ដែលជាការល្អទៅវិញសម្រាប់ឧស្សាហកម្ម និងការធ្លាក់ចុះនៃតម្លៃប្រេង គឺជាសញ្ញាមួយល្អសម្រាប់ប្រទេសនាំចូលប្រេងដូចកម្ពុជា។ ចំណែកវិស័យសារពើពន្ធអនុវត្តទៅតាមការគ្រោង ដោយខិតខំបង្កើនប្រសិទ្ធភាពលើការប្រមូលពន្ធ និងការចំណាយត្រូវបានបន្តត្រួតពិនិត្យយ៉ាងម៉ត់ចត់ ក្នុងន័យបង្កើនប្រសិទ្ធភាពសន្សំសំចៃថវិកា និងការផ្តល់សេវាឱ្យកាន់តែប្រសើរឡើង។

[ព័ត៌មានលម្អិត ...] កាលបរិច្ឆេទ៖ September 16, 2015

តារាងប្រតិបត្តិការហិរញ្ញវត្ថុ និង សេដ្ឋកិច្ចសម្រាប់ ខែ ឧសភា ឆ្នាំ ២០១៥ (TOFE for May 2015) នៅដើមឆ្នាំ ២០១៥ គិតត្រឹមខែឧសភា សកម្មភាពសេដ្ឋកិច្ចមានការរីកចំរើននិងរួមបន្ថស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច តាមរយៈការរក្សាស្ថិរភាពអត្រាប្តូរប្រាក់ និងកាត់បន្ថយអតិផរណា។ ចំណែកសកម្មភាពសេដ្ឋកិច្ចនៅតាមវិស័យនីមួយៗនៅតែបន្តកើនឡើងល្អ ដូចជាការកើនឡើងផ្នែកនាំចេញផលិតផលកសិកម្ម និងផលិតផលឧស្សាហកម្មនានា និងកំណើនការនាំចូលសម្ភារៈសំណង់។ សកម្មភាពនេះបានធ្វើរុញឱ្យមានកំណើននៃ ការប្រមូលចំណូលពន្ធពាណិជ្ជកម្មនិងពន្ធដារ។ ក្នុងសកម្មភាពកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈបានរួមចំណែកធ្វើឱ្យវិស័យសារពើពន្ធនៅបន្តកើនឡើង ដោយសារការខិតខំបង្កើនប្រសិទ្ធភាពលើការប្រមូលពន្ធ និងការចំណាយត្រូវបានបន្តត្រួតពិនិត្យយ៉ាងម៉ត់ចត់ក្នុងន័យបង្កើនប្រសិទ្ធភាព សន្សំសំចៃថវិកា និងការផ្តល់សេវាឱ្យកាន់តែប្រសើរឡើង។

[ព័ត៌មានលម្អិត ...] កាលបរិច្ឆេទ៖ August 12, 2015

តារាងប្រតិបត្តិការហិរញ្ញវត្ថុ និង សេដ្ឋកិច្ចសម្រាប់ ខែ មេសា ឆ្នាំ ២០១៥ (TOFE for April 2015) នៅដើមឆ្នាំ ២០១៥ គិតត្រឹមខែមេសា ស្ថានភាពម៉ាក្រូសេដ្ឋកិច្ចត្រូវការគ្រប់គ្រងនិងមានស្ថិរភាព ដូចជាស្ថេរភាពអត្រាប្តូរប្រាក់ និង អតិផរណាមានកម្រិតទាប។ ចំណែកសកម្មភាពសេដ្ឋកិច្ចនៅតាមវិស័យនីមួយៗ នៅតែបន្តកើនឡើងល្អ ដូចជាមានការកើនឡើងទាបជាងការរំពឹងទុកផ្នែកនាំចេញផលិតផលកសិកម្ម និងផលិតផលឧស្សាហកម្មនានា និងការកើនឡើងការនាំចូលសម្ភារៈសំណង់ ទោះបីជាមានការថមថយបន្តិចលើ វិស័យទេសចរណ៍ក៏ដោយ។ ចំណែកវិស័យសារពើពន្ធនៅបន្តកើនឡើង ដោយសារការខិតខំបង្កើនប្រសិទ្ធភាពលើការប្រមូលពន្ធ និងការចំណាយត្រូវបានបន្តត្រួតពិនិត្យយ៉ាងម៉ត់ចត់ក្នុងន័យបង្កើនប្រសិទ្ធភាព, សន្សំសំចៃថវិកា និងការផ្តល់សេវាឱ្យកាន់តែប្រសើរឡើង។

[ព័ត៌មានលម្អិត ...] កាលបរិច្ឆេទ៖ June 09, 2015

1 2 3 4 5 >

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
Ministry of Economy and Finance

St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, Cambodia
Tel: 855-23-724 664 / Fax: 855-23-427 798
Email: admin@mef.gov.kh

© 2012, Managed by MEF Web master